ASIAN PACIFIC HEALTH CARE VENTURE, INC.
"working together for community health"

Affix the label here

# លិខិតបញ្ជាក់ផ្តល់សិទ្ធិអនុញ្ញាតនៃអ្នកថែរក្សា

ការប្រើប្រាស់លិខិតបញ្ជាក់នេះត្រូវបានអនុញ្ញាតតាមរយៈផ្នែក១.៥(ចាប់ផ្តើមឡើងជាមួយផ្នែក៦៥៥០)នៃឌីវីស្យិនទី១១ក្នុងក្រមសារនៃរដ្ឋកាលីហ្វញ៉ា។

***ការណែនាំ៖*** ការបំពេញពីលេខ១-៤និងការចុះហត្ថលេខាលើលិខិតបញ្ជាក់ គឺគ្រប់គ្រាន់ក្នុងការចុះឈ្មោះអនុញ្ញាតដល់អនីតិជនអោយចូលសាលារៀន និងអនុញ្ញាតអោយផ្តល់ការថែរក្សាផ្នែកវេជ្ជសាស្រ្តនៅក្នុងសាលារៀន។ ការបំពេញពីលេខ៥-៨ គឺជាតម្រូវការបន្ថែមក្នុងការផ្តល់សិទ្ធិទៅលើការថែរក្សាផ្នែកវេជ្ជសាស្រ្តដ៏ទៃទៀត។ សូមសរសេរអោយបានច្បាស់។

អនីតិជនដែលមានឈ្មោះខាងក្រោមនេះ រស់នៅក្នុងផ្ទះរបស់ខ្ញុំ ហើយខ្ញុំមានអាយុ១៨ឆ្នាំ រឺច្រើនជាងនេះ។

១. ឈ្មោះអនីតិជន៖ ______________________________

២. ខែ-ថ្ងៃ-ឆ្នាំកំណើតរបស់អនីតិជន៖______________________________

៣. ឈ្មោះរបស់ខ្ញុំ៖______________________________

(មនុស្សពេញវ័យដែលជាអ្នកផ្តល់ការអនុញ្ញាត)

៤. អាស័យដ្ឋានផ្ទះរបស់ខ្ញុំ៖______________________________

______________________________

៥. [ ]ខ្ញុំគឺជាជីដូនជីតា, ម្តាយធំរឺម្តាយមីង, ឪពុកធំរឺឪពុកមា, រឺជាសាច់ញាតិដទៃទៀតដែលមានសិទ្ធិទទួលខុសត្រូវលើអនីតិជន(សូមអានអត្ថន័យនៃ "សាច់ញាតិដែលមានសិទ្ធិ" នៅផ្នែកខាងក្រោយនៃក្រដាសនេះ)។

៦. សូមគូសសញ្ញា(✓)ក្នុងប្រអប់មួយរឺទាំងពីរ(ឧទាហរណ៍ ប្រសិនបើមានឪពុក រឺម្តាយតែម្នាក់ត្រូវបានផ្តល់ដំបូន្មាន ហើយម្នាក់ទៀតមិនអាចរកឃើញ)៖

[ ] ខ្ញុំបានផ្តល់ដំបូន្មានដល់ឪពុក ម្តាយ រឺជនដែលមានសិទ្ធិមើលថែអនីតិជនស្របច្បាប់ អំពីគោលបំណងរបស់ខ្ញុំក្នុងការផ្តល់សិទ្ធិថែរក្សាផ្នែកវេជ្ជសាស្រ្តដោយមិនបានទទួលការបដិសេធទេ។

[ ] ខ្ញុំមិនអាចទាក់ទងឪពុក ម្តាយ រឺជនដែលមានសិទ្ធិមើលថែអនីតិជនស្របច្បាប់ក្នុងពេលនេះ ដើម្បីប្រាប់គេអំពីការអនុញ្ញាតិដែលបានគ្រោងទុករបស់ខ្ញុំ។

៧. ខែ-ថ្ងៃ-ឆ្នាំកំណើតរបស់ខ្ញុំ៖______________________________

៨. លេខប័ណ្ណបើកបរឬប័ណ្ណសំគាល់ខ្លួនរបស់ខ្ញុំ៖______________________________

***ការព្រមាន៖ សូមកុំចុះហត្ថលេខាលើឯកសារនេះប្រសិនបើសេចក្តីថ្លែងការណ៍ខាងលើមិនត្រឹមត្រូវ រឺបើមិនដូច្នេះទេ អ្នកនឹងត្រូវផ្តន្ទាទោសពីការប្រព្រឹត្តបទល្មើសតាមរយៈ ការផាកពិន័យ ការដាក់ព័ន្ធនាគារ រឺទាំងពីរ។***

ខ្ញុំសូមប្រកាសក្រោមទោសបញ្ញាតិនៃការភូតកុហកក្រោមច្បាប់នៃរដ្ឋកាលីហ្វញ៉ាថាអ្វីដែលខ្ញុំបានលើកឡើងខាងលើគឺពិតប្រាកដនិងត្រឹមត្រូវ។

ខែ-ថ្ងៃ-ឆ្នាំ៖______________________________

ហត្ថលេខា៖______________________________

(អ្នកតំណាងស្របច្បាប់)

ឈ្មោះ៖ ______________________________

(អ្នកតំណាងស្របច្បាប់)

សូមចំណាំ៖

- ចំពោះការថែទាំ សិទ្ធិព្យាបាល និងការមើលខុសត្រូវអនីតិជន សេចក្តីប្រកាសនេះមិនប៉ះពាល់ដល់សិទ្ធិរបស់ឪពុកម្តាយ រឺអាណាព្យាបាលស្របច្បាប់របស់អនីតិជន ហើយក៏មិនមានន័យថាអ្នកផ្តល់ការថែរក្សាមានសិទ្ធិមើលថែរក្សាយ៉ាងស្របច្បាប់ចំពោះអនីតិជនដែរ។
- ជនដែលពឹងផ្អែកលើលិខិតបញ្ជាក់នេះ គឺមិនមានកាតព្វកិច្ចក្នុងការធ្វើការសាកសួររឺការស៊ើបអង្កេតបន្តទៀតទេ។

---

***ពត៌មានសំខាន់***

---

**ចំពោះអ្នកផ្តល់ការថែរក្សា៖**

អត្ថន័យខទី៥ខាងលើ "សាច់ញាតិដែលមានសិទ្ធិ" គឺសំដៅទៅលើប្តីប្រពន្ធ, ឪពុកម្តាយ, ឪពុកម្តាយចុង, បងរឺប្អូនប្រុស, បងរឺប្អូនស្រី, បងរឺប្អូនប្រុសដែលជាកូនរបស់ឪពុកម្តាយចុង, បងរឺប្អូនស្រីដែលជាកូនរបស់ឪពុកម្តាយចុង, បងរឺប្អូនប្រុសដែលមានម្តាយទីទៃរឺមានឪពុកទីទៃ បងរឺប្អូនស្រីដែលមានម្តាយទីទៃរឺមានឪពុកទីទៃពីគ្នា, ឪពុកធំរឺឪពុកមា, ម្តាយធំរឺម្តាយមីង, ក្មួយស្រី, ក្មួយប្រុស, បងប្អូនជីដូនមួយ រឺជនដែលមានងារផ្តើម ដោយពាក្យ"ជីដូន" រឺ "ជីទួត" រឺប្តីរឺក៏ប្រពន្ធរបស់ ជនដែលបានបញ្ជាក់ ក្នុងអត្ថន័យនេះ ទោះបីជាអាពាពិពាហ៍ត្រូវបានបញ្ចប់ដោយការស្លាប់រឺការលែងលះក៏ដោយ។

ប្រសិនបើអ្នកមិនមែនជាសាច់ញាតិ រឺបច្ចុប្បន្ននេះអ្នកគឺជាឪពុកម្តាយចញ្ចឹមដែលមានអាជ្ញាប័ណ្ណ ដើម្បីចិញ្ចឹមក្មេងក្រោមអាយុ ច្បាប់អាចតម្រូវអោយផ្ទះរបស់អ្នកត្រូវមានអាជ្ញាបណ្ណ៍ ចិញ្ចឹមក្មេងយ៉ាងស្របច្បាប់ ។ ប្រសិនបើអ្នកមានសំណួរ សូមទាក់ទងទៅក្រសួងសង្គមកិច្ចដែលនៅក្នុងតំបន់របស់អ្នក។

ប្រសិនបើអនីតិជនឈប់រស់នៅជាមួយអ្នក អ្នកនឹងត្រូវតម្រូវអោយផ្តល់ដំណឹងទៅទីកន្លែងដែលអ្នកធ្លាប់បានផ្តល់លិខិតបញ្ជាក់នេះទៅគេ ដូចជា សាលារៀន គ្រូពេទ្យប្រចាំខ្លួន រឺគំរោងសេវាកម្មសុខភាព ។

ប្រសិនបើអ្នកគ្មានពត៌មានដែលត្រូវបានស្នើសុំនៅខទី៨ខាងលើទេ(លេខប័ណ្ណបើកបរឬប័ណ្ណសំគាល់ខ្លួន) សូមផ្តល់ប័ណ្ណសំគាល់ខ្លួនផ្សេងទៀតដូចជាលេខសុសស្យុល(SSN#) រឺលេខមេឌីកាល់។

**ចំពោះបុគ្គលិកនៅសាលារៀន៖**

តាមមាត្រាលេខ៤៨២០៤ នៃបទបញ្ញត្តិផ្នែកការសិក្សាអប់រំបានថែងថាលិខិតបញ្ជាក់នេះគឺចាត់ទុកថាគ្រប់គ្រាន់ ក្នុងការបញ្ជាក់អំពីទីលំនៅដ្ឋានរបស់កុមារ ដោយគ្មានតម្រូវការបង្គាប់ បញ្ជោរទៅអ្នកអាណាព្យាបាលរឺអ្នកដែលមានសិទ្ធិមើលថែដ៏ទៃទៀតឡើយ លុះត្រាតែសាលារៀនប្រចាំសង្កាត់ធ្វើការកំណត់ថាការពិតកុមារមិនបានរស់នៅជាមួយអ្នកផ្តល់ការថែរក្សា។

សាលារៀនប្រចាំសង្កាត់ អាចទាមទារភស្តុតាងសមហេតុផលបន្ថែម ថាអ្នកផ្តល់ការថែរក្សានោះ រស់នៅអាស័យដ្ឋានដែលបានផ្តល់នៅខទី៤ខាងលើ។

**ចំពោះគ្រូពេទ្យប្រចាំខ្លួន និងគំរោងសេវាកម្មសុខភាព៖**

បុគ្គលដែលជាអ្នកសំរេចទទួលការជឿទុកចិត្ត នៅពេលដែលអ្នកផ្តល់ការថែរក្សាកុមារបានប្រគល់សិទ្ធិអនុញ្ញាតិនៅលើក្រដាស់បញ្ជាក់ ដើម្បីផ្តល់ការថែរក្សាផ្នែកវេជ្ជសាស្រ្ត រឺ ផ្នែកសុខភាពធ្មេញដល់កុមារ។ ដោយសារតែមិនបានយល់ដឹងអំពីការពិតដែលអាចផ្ទុយទៅនឹងអ្វីដែលមានចុះនៅលើក្រដាស់បញ្ជាក់នៅក្នុងថ្ងៃខែដែលបានចុះលើក្រដាសនោះ ការធ្វើនេះនឹងមិនទទួលខុសត្រូវចំពោះ បទឧក្រិដ្ឋ រឺច្បាប់រដ្ឋប្បវេណីលើបុគ្គលណាម្នាក់ឡើយ រឺនឹងមិនទទួលខុសត្រូវចំពោះការប្តឹងផ្តល់ដាក់ទណ្ឌកម្មទៅតាមច្បាប់ទេ។ ជំនឿទុកចិត្តនោះគឺគ្រាន់តែជាចំណែកនៃក្រដាសដែលត្រូវបំពេញអោយបានគ្រប់ប៉ុណ្ណោះ។

លិខិតបញ្ជាក់នេះមិនមែនមានន័យថាអនីតិជនមានគោលបំណងចូលរួមក្នុងគំរោងសុខភាពដោយស្វ័យប្រវត្តិនោះទេ។

Reference: Family Code Sections 6550 to 6552